# សាកលវិទ្យាល័យបៀលប្រាយ
# BUILD BRIGHT UNIVERSITY



អនាគតរបស់លោកអ្នកកាន់តែភ្លឺស្វាង ដោយបៀលប្រាយ

Your Future's **Brighter** with **Build Bright**





**ឆ្នាំសិក្សា** | **Academic Year 2024 - 2025**

ទិដ្ឋាការអនុញ្ញាតលេខ: 14/2024 គ.ព.ខ.រ.ផ


023 987 700
012/015 682 777
bbu.edu.kh
bbu.edu.kh
info@bbu.edu.kh

# ផែនទីកម្ពុជា ទីតាំងសាកលវិទ្យាល័យប៊ៀលប្រាយ » Build Bright University Campuses Cambodia Map




អនាគតរបស់លោកអ្នកកាន់តែភ្លឺស្វាង ដោយប៊ៀលប្រាយ

Your Future's **Brighter** with **Build Bright**

# សារប្រធានក្រុមប្រឹក្សាភិបាល



***ខ្ញុំសូមថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្ដៅដល់និស្សិតទាំងអស់ដែលបាននិងកំពុងជ្រើសរើសសាកលវិទ្យាល័យបៀលប្រាយ «Build Bright University - BBU» ជាកន្លែងសិក្សាបានទាំងបរិមាណនិងគុណភាព ដើម្បីឲ្យខ្លួនប្រសើរឡើង គ្រួសាររីកចម្រើន និងប្រទេសជាតិរុងរឿង ស្របតាមទស្សនាទានថា «ការអប់រំល្អ គឺជាកូនសោសម្រាប់ដោះស្រាយរាល់បញ្ហាសង្គម និងសេដ្ឋកិច្ចជាតិ»***

ការអប់រំឧត្តមសិក្សាត្រូវបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេញលេញនិងជំរុញការស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម ដើម្បីឲ្យមានសមត្ថភាពខ្ពស់ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាពសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ។

រាជរដ្ឋាភិបាលគ្រប់អាណត្តិ បានកំណត់រួចហើយថា **ការកសាងធនធានមនុស្ស** គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាពឆ្ពោះទៅកាន់ការកាត់បន្ថយជាបណ្ដើរៗនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋ លើសពីនេះទៅទៀត **ការអភិវឌ្ឍធនធានមនុស្ស**ត្រូវបានចាត់ទុកជាអាទិភាពនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណនៅគ្រប់ដំណាក់កាល ពិសេសបានក្លាយជាអាទិភាពទី១ នៅក្នុងដំណាក់កាលទី៣និងទី៤ **និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១** សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិកាស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពល្អ និងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម។ ក្នុងន័យនេះ **ការអភិវឌ្ឍធនធានមនុស្សក្នុងនីតិកាលទី៧** នេះនឹងបន្តផ្តោតលើៈ ១. ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ២. ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ៣. ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ៤. ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង និង ៥. ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអរិយធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។ ជាងនេះទៅទៀត ការបង្កើនភាពឆ្លើយតបឲ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារនិងការរស់នៅ តាមរយៈទស្សនាទាន **«យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត»** រៀបចំកម្មវិធីបង្កើតគំនិតសហគ្រិនភាពនិងភាសាបរទេស ពង្រឹងការអប់រំ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា **«Science Technology Engineering, and Mathematics - STEM»** ដោយបង្កើតឲ្យមានមជ្ឈមណ្ឌលអប់រំនិងវិទ្យាសាស្ត្រ បន្តជំរុញកម្មវិធីបំណិនជីវិត ពិសេសកម្មវិធីយុវជននិងភាពជាអ្នកដឹកនាំ សីលធម៌និងជីវិតក្នុងការរស់នៅ និងការចូលរួមការងារសង្គមនិងបរិស្ថាន។

ក្រសួងអប់រំ យុវជន និងកីឡា ក៏បានយកចិត្តទុកដាក់ដោយផ្តោតលើការរៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយរួមទាំងការបញ្ចូល STEM និងវិទ្យាសាស្ត្រសង្គមគន្លឹះៗ សម្រាប់ឧត្តមសិក្សាស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដាតំបន់ និងអន្តរជាតិ ការពង្រឹងយន្តការ ការទទួលស្គាល់គុណភាពឧត្តមសិក្សា ការបង្កើនចំនួនសាស្ត្រាចារ្យប្រកបដោយគុណភាពនៅឧត្តមសិក្សា ការបង្កើនការវិនិយោគលើឧត្តមសិក្សានិងបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិ សំដៅអភិវឌ្ឍន៍មូលនិធិអាហារូបករណ៍ និងឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា ការជំរុញការអភិវឌ្ឍសមត្ថភាពនិងធនធានសម្រាប់ការគាំទ្រការរៀន ការបង្រៀន ការសិក្សាស្រាវជ្រាវ និងនវានុវត្តន៍ ការបង្កើតមូលនិធិសិក្សាស្រាវជ្រាវនិងនវានុវត្តន៍ និងយន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ ការបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិ ស្ដីពី អភិបាលកិច្ចនិងការគ្រប់គ្រងឧត្តមសិក្សាព្រមទាំងកំណែទម្រង់វិស័យឧត្តមសិក្សា។

ជាមួយផែនការយុទ្ធសាស្ត្រត្រីកោណនៃការអភិវឌ្ឍសាកលវិទ្យាល័យបៀលប្រាយ មាន**ចក្ខុវិស័យគឺអប់រំអ្នកសិក្សាទាំងអស់ដែលនឹងទទួលជោគជ័យនិងផ្តល់ផលជះជាវិជ្ជមានដល់សង្គម។** ដើម្បីអនុវត្តតាមចក្ខុវិស័យខាងលើ សាកលវិទ្យាល័យបៀលប្រាយ មានបេសកកម្មផ្តោតលើ **១. ផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ ២. ដោះស្រាយបញ្ហាប្រឈមក្នុងសង្គម និងតម្រូវការសហគមន៍ ៣. លើកកម្ពស់ការស្រាវជ្រាវទាន់សម័យ នវានុវត្តន៍ បរិវត្តកម្មឌីជីថល និងបរិយាបន្ន ៤. ជំរុញសហគមន៍ចម្រុះនៃអ្នកសិក្សាពេញមួយជីវិតដែលរួមចំណែកយ៉ាងមានអត្ថន័យដល់សង្គម ៥. ផ្តល់អំណាចដល់និស្សិត និងសាស្ត្រាចារ្យឲ្យសម្រេចបាននូវសក្តានុពលពេញលេញតាមរយៈកម្មវិធីសិក្សាអប់រំផ្នែកសិល្បៈសេរី «វិទ្យាសាស្ត្រសង្គម» និងវិទ្យាសាស្ត្រ ជីគត់មត់ ប្រកបដោយនវានុវត្តន៍ និងបរិវត្តកម្ម ៦. ប្តេជ្ញាក្នុងការលើកកម្ពស់គុណភាពនិងការកែលម្អជានិរន្តរ៍នៃសេវាអប់រំ។** ជានេះទៅទៀត សាកលវិទ្យាល័យបៀលប្រាយ ក៏មាន**គោលបំណងរៀបចំអ្នកសិក្សាទាំងអស់ឲ្យក្លាយជាពលរដ្ឋចូលរួមយ៉ាងសកម្ម មានអាជីពប្រកបដោយឥទ្ធិពល និងអនាគតកាន់តែភ្លឺស្វាង។**

ដើម្បីសម្រេចបានតាមចក្ខុវិស័យ បេសកកម្ម និងគោលបំណងខាងលើសាកលវិទ្យាល័យបៀលប្រាយ មានគោលដៅជាយុទ្ធសាស្ត្រដោយផ្តោតលើ **១. រក្សាឲ្យបាននូវវប្បធម៌និងគំនិតផ្តួចផ្តើមអំពីគុណភាព ២. ពង្រឹងនិងពង្រីកនូវទំនាក់ទំនងខាងក្រៅ ការផ្សព្វផ្សាយព័ត៌មាន និងប្រតិបត្តិការទីផ្សារឲ្យកាន់តែប្រសើរនិងទូលំទូលាយឡើង ៣. ពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចល្អនិងភាពជាអ្នកដឹកនាំ ៤. លើកកម្ពស់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៥. ពង្រឹងការរៀបចំផែនការស្ថាប័ននិងអប់រំ ៦. ផ្តល់ការសិក្សា ការបង្រៀន ការស្រាវជ្រាវ និងនវានុវត្តន៍ ដែលមានប្រសិទ្ធភាព ៧. ប្តេជ្ញាផ្តល់ឧត្តមភាពនៃការសិក្សាអប់រំ ការស្រាវជ្រាវ និងនវានុវត្តន៍ ៨. ផ្តល់នូវវិសាលភាពសិក្សាអប់រំកាន់តែទូលំទូលាយ ៩. ផ្តល់សេវាកម្មអតិថិជនឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ១០. ផ្តល់សេវាកម្ម គាំទ្រផ្សេងៗដល់និស្សិតឲ្យមានប្រសិទ្ធភាព ១១. ធ្វើទំនើបកម្មសម្ភារៈរូបវន្តនិងធនធានការសិក្សា ១២. កែលម្អឲ្យប្រសើរឡើង និងលើកកម្ពស់ស្តង់ដានិងការធានាគុណភាពអប់រំផ្នែកក្នុងទាំងកម្រិតគ្រឹះស្ថានទាំងមូលនិងកម្រិតសិក្សានីមួយៗ។**

តាងនាមក្រុមប្រឹក្សាភិបាលខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់គ្នាដែលបាននិងកំពុងធ្វើការជាមួយគិតអំពីនិងជ្រើសរើសសាកលវិទ្យាល័យបៀលប្រាយ ជាកន្លែងសិក្សាបានទាំងបរិមាណនិងគុណភាព។ សាកលវិទ្យាល័យបៀលប្រាយ គឺជាគ្រឹះស្ថានឧត្តមសិក្សាឯកជនធំជាងគេមានទីតាំងគោលរាជធានីនិងសាខាខេត្តចំនួនប្រាំបួន ដែលបាននិងកំពុងផលិតធនធានមនុស្សចំនួនជិត ១២ម៉ឺននាក់ ក្នុងរយៈពេលជាង២៤ឆ្នាំកន្លងទៅ។

ខ្ញុំសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងសាកលវិទ្យាល័យបៀលប្រាយគ្រប់លំដាប់ថ្នាក់ ក៏ដូចជាបុគ្គលិក សាស្ត្រាចារ្យទាំងអស់ដែលបានបំពេញការងារយ៉ាងសកម្ម និងមិនចេះនឿយហត់ ដើម្បីអនាគតដ៏រុងរឿងរបស់កម្ពុជា។ ខ្ញុំក៏ថ្លែងអំណរគុណដល់និស្សិតទាំងអស់ដែលបានខិតខំរៀនសូត្រ ដើម្បីឲ្យខ្លួនប្រសើរឡើង គ្រួសាររីកចម្រើន និងប្រទេសជាតិមានវិបុលភាព។ ប្រសិនបើយើងមិនខិតខំតស៊ូធ្វើការយ៉ាងស្វិតស្វាញជាមួយគ្នាដោយភាពសុខដុមរមនាទេនោះ សុបិនរបស់យើងមិនអាចក្លាយជាការពិតបានឡើយ។

**ដោយសេចក្តីគោរពរាប់អានពីខ្ញុំ**
**សាស្ត្រាចារ្យ បណ្ឌិត អ៊ីន វីរជាតិ**

# សារសាកលវិទ្យាធិការ

## ចំពោះ ក្មួយៗសិស្សានុសិស្សទាំងអស់ជាទីស្រឡាញ់រាប់អានបំផុត.!



ខ្ញុំពិតជារំភើពរីករាយនិងសូមអបអរសាទរចំពោះការឈានមកដល់ដំណាក់កាលដ៏សំខាន់មួយនេះ ក្នុងដំណើរការសិក្សាដ៏វែងឆ្ងាយ ហើយដែលពេលនេះទាំងអស់គ្នាកំពុងតែរៀបចំបន្តដំណើរពីវិទ្យាល័យឆ្ពោះមកសាកលវិទ្យាល័យ ហើយឆ្លៀតឱកាសនេះផងដែរ ខ្ញុំសូមសម្តែងនូវគារវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះក្មួយៗសិស្សានុសិស្សទាំងអស់។

យើងខ្ញុំទាំងអស់គ្នាមានសេចក្តីសោមនស្សរីករាយជាពន់ពេកដោយបានទទួលស្វាគមន៍ អ្នកសិក្សាជំនាន់ថ្មីរបស់យើងមកចូលរួមក្នុងសហគមន៍សិក្សាដ៏ធំនៃសាកលវិទ្យាល័យបៀលប្រាយ ដែលមាននិស្សិត អតីតនិស្សិត និងបុគ្គលិកសិក្សាជាង១១ម៉ឺននាក់ នៅតាមរាជធានី-សាខាខេត្តទាំងប្រាំបួន ស្ថិតក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តត្បូងឃ្មុំ។ ដំណាក់កាលនេះគឺជាពេលវេលានៃការចាប់ផ្តើមថ្មីពោរពេញដោយឱកាសក្នុងការសិក្សាស្វែងយល់ការអភិវឌ្ឍរីកចម្រើន និងការកសាងទំនាក់ទំនងមួយដ៏យូរអង្វែង។

សាកលវិទ្យាល័យប្តេជ្ញាផ្តល់នូវបរិយាកាសអភិវឌ្ឍន៍ និងការលើកទឹកចិត្តមួយដែលពោរពេញដោយឱកាសសម្រាប់ការរីកលូតលាស់ ការសិក្សាស្វែងយល់ និងការបង្កើតស្នាដៃស្រាវជ្រាវ។ល។ សាកលវិទ្យាល័យផ្តល់ជូននូវកម្មវិធីនិងធនធានសិក្សាក៏ដូចធនធានរូបវន្តជាច្រើន ដើម្បីជួយគាំទ្រដល់ក្មួយៗសិស្សានុសិស្សព្រមទាំងអ្នកសិក្សាជាច្រើនទៀតឲ្យសម្រេចបាននូវគោលដៅរបស់ខ្លួន។ ក្នុងសាកលវិទ្យាល័យក្មួយៗនឹងបង្កើតនូវទំនាក់ទំនងថ្មីទៀតជាមួយមនុស្សជាច្រើន ស្វែងរកឃើញគំនិតថ្មីៗ និងអភិវឌ្ឍជំនាញជាច្រើនដែលនឹងកំណត់អនាគតរបស់ក្មួយៗ។

ពេលនេះក្មួយៗចាប់ផ្តើមទំព័រថ្មីនៃការសិក្សានៅសាកលវិទ្យាល័យបៀលប្រាយ គ្រប់សាខារាជធានី-ខេត្តទាំងប្រាំបួន បរិយាកាសនៃការសិក្សាទាំងក្នុងនិងក្រៅសាកលវិទ្យាល័យ នឹងមិនទុកឲ្យក្មួយៗនៅតែម្នាក់ឯងទេ សាស្ត្រាចារ្យ បុគ្គលិក និងនិស្សិតនៅទីនេះទាំងអស់នឹងនៅជាមួយក្មួយៗដើម្បីជាជំនួយក្នុងការណែនាំ និងគាំទ្រគ្រប់ដំណាក់កាលនៃដំណើរការសិក្សារបស់ក្មួយៗ។ ខ្ញុំសូមលើកទឹកចិត្តដល់ក្មួយៗ ឲ្យព្យាយាមប្រើប្រាស់ឱកាសដែលមានសម្រាប់ក្មួយៗទាំងអស់ដើម្បីចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាល សិក្សា និងស្រាវជ្រាវជាមួយសាកលវិទ្យាល័យបៀលប្រាយ និងទាញយកអត្ថប្រយោជន៍ជាចំណេះដឹង ជំនាញ និងការអនុវត្តជាក់ស្តែងពីការចូលរួមក្នុងសកម្មសាកលវិទ្យាល័យឲ្យបានច្រើនបំផុតហើយកុំស្ទាក់ស្ទើរក្នុងការចោទសំណួរ ឬ ស្នើសុំសេវាគាំទ្រការសិក្សាជាច្រើនទៀតតាមតម្រូវការនិងគោលដៅសិក្សារបស់ក្មួយៗ។

សាកលវិទ្យាល័យបៀលប្រាយ គឺជាពេលវេលាមួយដើម្បីឲ្យក្មួយៗស្វែងរកឲ្យឃើញពីចំណង់ចំណូលចិត្តរបស់ខ្លួនពីសមត្ថភាពប្រកួតប្រជែងនឹងបញ្ហាប្រឈមជាក់ស្តែង ពីចំណាប់អារម្មណ៍ថ្មីៗ ការទទួលយកបញ្ហាប្រឈម និងការសាទរចំពោះភាពជោគជ័យដែលក្មួយៗសម្រេចបាន។ បទពិសោធន៍ ដែលក្មួយៗទទួលបានជាមួយសាកលវិទ្យាល័យមិនថាល្អ ឬ អាក្រក់គឺជាចំណែកមួយដែលមានតម្លៃ ឆ្លុះបញ្ចាំងពីការរីកចម្រើននៃគំនិតនិងសមត្ថភាពរបស់ក្មួយៗក្នុងការឆ្លើយតប និងដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងក្នុងពេលបច្ចុប្បន្ននិងអនាគត។

យើងខ្ញុំទាំងអស់គ្នាមានជំនឿជាក់យ៉ាងម៉ត់មាំថា ពេលមកដល់សាកលវិទ្យាល័យបៀលប្រាយ ក្មួយៗទាំងអស់នឹងរកឃើញថា វាជាទីកន្លែងដែលជួយឲ្យក្មួយៗទទួលបាននូវការរីកចម្រើនយ៉ាងពិតប្រាកដទាំងចំណេះដឹង ជំនាញ ការអនុវត្តជាក់ស្តែង ព្រមទាំងបង្កើតនូវទំនាក់ទំនងមួយដ៏យូរអង្វែង។ យើងខ្ញុំទាំងអស់គ្នាទន្ទឹងរង់ចាំស្វាគមន៍ និងគាំទ្រសកម្មភាពសិក្សារបស់ក្មួយៗដែលសម្រេចចិត្តចូលរួម ជាមួយសហគមន៍សិក្សាសាកលវិទ្យាល័យបៀលប្រាយ។

ខ្ញុំសូមស្វាគមន៍និងជូនពរក្មួយៗសិស្សានុសិស្សទាំងអស់ សូមឲ្យមានសំណាងល្អ សម្រេចជោគជ័យក្នុងការសិក្សា និងទទួលបានលទ្ធផលត្រឹមត្រូវដូចការរំពឹងទុក។

**ដោយក្តីគោរពនិងស្រឡាញ់រាប់អានបំផុតពីខ្ញុំ**

**សាស្ត្រាចារ្យ ឌៀប សីហា**

**សា**កលវិទ្យាល័យបៀលប្រាយ គឺជាគ្រឹះស្ថានឧត្តមសិក្សាធំជាងគេក្នុងប្រទេសកម្ពុជាដែលបានផ្តល់ការអប់រំនិងបណ្តុះបណ្តាលកម្រិតឧត្តមសិក្សាដល់យុវជន និងអ្នកសិក្សាស្រាវជ្រាវជិត **១២ម៉ឺននាក់**ចាប់តាំងពីឆ្នាំ២០០០ រហូតមកដល់បច្ចុប្បន្ន។ សាកលវិទ្យាល័យបាននឹងបន្តការអប់រំនិងបណ្តុះបណ្តាលជំនាញ/ឯកទេសជាច្រើនចាប់ពីកម្រិត**បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងកម្រិតបណ្ឌិត** ក្នុងវិស័យគ្រប់គ្រងធុរកិច្ច វិស័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសង្គម វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច វិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា វិស័យវិស្វកម្មនិងស្ថាបត្យកម្ម វិស័យសិល្បៈ មនុស្សសាស្ត្រនិងភាសា និងវិស័យសេដ្ឋកិច្ច និងវិទ្យាសាស្ត្រកសិកម្ម។ ខាងក្រោមជាព័ត៌មានសង្ខេបអំពីការកកើតនិងដំណើរការអភិវឌ្ឍន៍សាកលវិទ្យាល័យបៀលប្រាយ៖

- សាស្ត្រាចារ្យ បណ្ឌិត **អ៊ីន វីរជាតិ** ជាស្ថាបនិកមហាវិទ្យាល័យគ្រប់គ្រងនិងនីតិសាស្ត្រឆ្នាំ២០០០ និងសាកលវិទ្យាល័យបៀលប្រាយឆ្នាំ២០០២ ហើយបច្ចុប្បន្នជាប្រធានក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យបៀលប្រាយ។
- សាកលវិទ្យាល័យបៀលប្រាយ មានរចនាសម្ព័ន្ធអភិបាលកិច្ចនិងសមាសភាពគណៈគ្រប់គ្រងជាន់ខ្ពស់ ឆ្នាំ២០២៤ រួមមាន៖

| | |
|---|---|
| **១. សាស្ត្រាចារ្យ បណ្ឌិត អ៊ីន វីរជាតិ** | ប្រធានក្រុមប្រឹក្សាភិបាលនិងជាស្ថាបនិក |
| **២. សាស្ត្រាចារ្យ បណ្ឌិត ហេង វង្សប៊ុនឆាត** | អនុប្រធានក្រុមប្រឹក្សាភិបាល |
| **៣. សាស្ត្រាចារ្យ ឡៅ សីហា** | សាកលវិទ្យាធិការ |
| **៤. សាស្ត្រាចារ្យ បណ្ឌិត ឌី ដាវុឌ្ឍ** | សាកលវិទ្យាធិការរងជាន់ខ្ពស់ |
| **៥. សាស្ត្រាចារ្យ អ៊ីន វីរជ័យ** | សាកលវិទ្យាធិការរង |
| **៦. លោកស្រី អ៊ីន វីរលក្ខិណា** | សាកលវិទ្យាធិការរង |

- មហាវិទ្យាល័យគ្រប់គ្រងនិងនីតិសាស្ត្រ «ម.គ.ន» ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០ និងដំណើរការបណ្តុះបណ្តាលក្នុងរាជធានីភ្នំពេញ ដោយមាននិស្សិតចុះឈ្មោះសិក្សាក្នុងឆ្នាំដំបូងសរុបជាង ៧០០នាក់។
- មហាវិទ្យាល័យគ្រប់គ្រង និងនីតិសាស្ត្រ បានអភិវឌ្ឍនិងប្រែក្លាយទៅជា **សាកលវិទ្យាល័យបៀលប្រាយ** «**ស.ប.ប.**» ក្នុងឆ្នាំ២០០២ និងបានពង្រីកវិសាលភាពនៃការអប់រំនិងបណ្តុះបណ្តាលយ៉ាងឆាប់រហ័សទាំងជំនាញឯកទេស និងកម្រិត សិក្សាក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តជាច្រើនក្នុងប្រទេស។
- សាកលវិទ្យាល័យបៀលប្រាយ បានសម្រេចនិងឆ្លងកាត់ពីរដំណាក់កាលនៃផែនការអភិវឌ្ឍ ឆ្នាំ២០០០ ដល់ឆ្នាំ២០២៤ ដោយបានពង្រីកវិសាលភាពអប់រំនិងបណ្តុះបណ្តាលនៅតាមទីតាំងគោលរាជធានី-សាខាខេត្តចំនួនប្រាំបួន៖

**១. ទីតាំងគោលរាជធានីភ្នំពេញ ឆ្នាំ២០០០**
**២. សាខាខេត្តសៀមរាប ឆ្នាំ២០០២**
**៣. សាខាខេត្តព្រះសីហនុ ឆ្នាំ២០០៣**
**៤. សាខាខេត្តរតនគិរី ឆ្នាំ២០០៣**
**៥. សាខាខេត្តតាកែវ ឆ្នាំ២០០៥**
**៦. សាខាខេត្តបាត់ដំបង ឆ្នាំ២០០៥**
**៧. សាខាខេត្តបន្ទាយមានជ័យ ឆ្នាំ២០០៦**
**៨. សាខាខេត្តស្ទឹងត្រែង ឆ្នាំ២០០៨**
**៩. សាខាខេត្តត្បូងឃ្មុំ ឆ្នាំ២០២២**



រាជធានីភ្នំពេញ


សាខាខេត្តសៀមរាប


សាខាខេត្តព្រះសីហនុ


សាខាខេត្តបាត់ដំបង



សាខាខេត្តតាកែវ





- សាកលវិទ្យាល័យបៀលប្រាយ កំពុងបន្តយុទ្ធសាស្ត្រអភិវឌ្ឍន៍**ដំណាក់កាលទីបី** ឆ្នាំ២០២២ ដល់ ឆ្នាំ២០៣០ នឹងគ្រោងបង្កើតនិងអភិវឌ្ឍន៍ពង្រីកបន្ថែមសាខាសាកលវិទ្យាល័យចំនួនពីរទីតាំងទៀត៖
  ១. សាខាខេត្តកណ្តាល ផែនការអភិឌ្ឍន៍សាខាថ្មី ឆ្នាំ២០២២ ដល់ ឆ្នាំ២០២៥
  ២. សាខាខេត្តកំពត ផែនការអភិឌ្ឍន៍សាខាថ្មី ឆ្នាំ២០២៦ ដល់ ឆ្នាំ២០៣០

- សាកលវិទ្យាល័យបៀលប្រាយ ផ្តល់ការអប់រំនិងបណ្តុះបណ្តាលជំនាញ/ឯកទេសជាច្រើនទាំងកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងកម្រិតបណ្ឌិត ដែលមានក្នុងមហាវិទ្យាល័យចំនួនប្រាំបី និងសាលាសិក្សាកម្រិតបណ្ឌិតមួយ៖

**១. មហាវិទ្យាល័យគ្រប់គ្រងធុរកិច្ច «Faculty of Business Administration»**
**២. មហាវិទ្យាល័យសេដ្ឋកិច្ច «Faculty of Economics»**
**៣. មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម «Faculty of Agricultural Sciences»**
**៤. មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសង្គម «Faculty of Law, and Social Sciences»**
**៥. មហាវិទ្យាល័យទេសចរណ៍និងបដិសណ្ឋារកិច្ច «Faculty of Tourism, and Hospitality»**
**៦. មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា «Faculty of Science, and Technology»**
**៧. មហាវិទ្យាល័យវិស្វកម្មនិងស្ថាបត្យកម្ម «Faculty of Engineering, and Architecture»**
**៨. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា «Faculty of Arts, Humanities, and Languages»**
**៩. សាលាសិក្សាកម្រិតបណ្ឌិត «School of Doctoral Studies»**

- សាកលវិទ្យាល័យបៀលប្រាយ បាននិងបន្តការអប់រំនិងបណ្តុះបណ្តាលនិស្សិតសរុបចំនួនជិត **១២ម៉ឺននាក់** ក្នុងនោះមាន៖
  ✓ និស្សិតបានបញ្ចប់ការសិក្សាដោយជោគជ័យ «អតីតនិស្សិត» សរុបចំនួន ១០៣ ៧៤៨នាក់ នារី ៣៧ ៦៦៤នាក់
  ✓ និស្សិតកំពុងសិក្សាសរុបចំនួន ១៣ ៣៧១នាក់ នារី ៦ ៨៧៥នាក់

- សាកលវិទ្យាល័យបៀលប្រាយ ទទួលនិស្សិតជាមធ្យម ឆ្នាំ២០០២ ដល់ ឆ្នាំ២០២៤ ចំនួនជាង ៥ ២០០នាក់ ក្នុងមួយឆ្នាំឲ្យចុះឈ្មោះសិក្សានៅតាមសាខារាជធានី-ខេត្តទាំងអស់។

- សាកលវិទ្យាល័យបៀលប្រាយ មានបុគ្គលិកសរុបឆ្នាំ២០២៤ ចំនួន១,០៣៦នាក់ នារី ១៨៨នាក់ ក្នុងនោះបុគ្គលិករដ្ឋបាលចំនួន ២៧០នាក់ នារី ១៣២នាក់ និងបុគ្គលិកអប់រំ/សាស្ត្រាចារ្យចំនួន ៧៦៦នាក់ នារី ៥៦នាក់ ដែលមានសាស្ត្រាចារ្យអន្តរជាតិសរុបចំនួន១៥នាក់ ក្នុងនោះនារីចំនួន៧នាក់។


សាខាខេត្តបន្ទាយមានជ័យ



សាខាខេត្តរតនគិរី


សាខាខេត្តស្ទឹងត្រែង


សាខាខេត្តត្បូងឃ្មុំ

# រចនាសម្ព័ន្ធអភិបាលកិច្ច
## សាកលវិទ្យាល័យប៊ែលប្រាយ

សាកលវិទ្យាល័យប៊ែលប្រាយ
Build Bright University



# ចក្ខុវិស័យ បេសកកម្ម និងគោលបំណង របស់សាកលវិទ្យាល័យបៀលប្រាយ

ស.ប.ប
BBU

## ចក្ខុវិស័យ

អប់រំអ្នកសិក្សាទាំងអស់ដែលនឹងទទួលជោគជ័យ
និងផ្ដល់ផលប្រយោជន៍វិជ្ជមានដល់សង្គម។

## គោលបំណង

រៀបចំអ្នកសិក្សាទាំងអស់ឲ្យក្លាយជាពលរដ្ឋល្អយ៉ាងសកម្ម
មានអាជីពប្រកបដោយឥទ្ធិពល និងអនាគតភ្លឺស្វាង។




## បេសកកម្ម

- ផ្ដល់ការអប់រំប្រកបដោយគុណភាពខ្ពស់
- ដោះស្រាយបញ្ហាប្រឈមក្នុងសង្គម និងតម្រូវការសហគមន៍
- លើកកម្ពស់ការស្រាវជ្រាវទាន់សម័យ នវានុវត្តន៍ បរិវត្តកម្មឌីជីថល និងបរិយាបន្ន
- ជំរុញសហគមន៍ចម្រុះនៃអ្នកសិក្សាពេញមួយជីវិត ដែលរួមចំណែកយ៉ាងមានអត្ថន័យដល់សង្គម
- ផ្ដល់អំណាចដល់និស្សិត និងសាស្ត្រាចារ្យឱ្យសម្រេចបាននូវសក្ដានុពលពេញលេញ តាមរយៈកម្មវិធីសិក្សា អប់រំផ្នែកសិល្បៈសេរី «វិទ្យាសាស្ត្រសង្គម» និងវិទ្យាសាស្ត្រ ដ៏តឹងតែង ប្រកបដោយនវានុវត្តន៍ និងបរិវត្តកម្ម
- ប្ដេជ្ញាក្នុងការលើកកម្ពស់គុណភាព និងការកែលម្អជានិរន្តរ៍នៃសេវាអប់រំ។

## Vision:

To educate learners who shall succeed and positively impact the society.

## Mission:

- To provide high-quality education.
- To address societal challenges and community needs.
- To promote cutting-edge research, innovation, digital transformation, and inclusivity.
- To foster a diverse community of lifelong learners who make meaningful contributions to society.
- To empower students and faculty to achieve their fullest potential through a rigorous, innovative, and transformative curriculum of liberal arts «social sciences» and sciences education.
- To commit to quality enhancement and continuous improvement of educational services.

## Purpose:

To prepare learners for impactful careers, engaged citizenship, and a brighter future.



# ហេតុផលដែលអ្នកត្រូវតែសម្រេចចិត្ត សិក្សានៅសាកលវិទ្យាល័យបៀលប្រាយ



✓ **មានកេរ្តិ៍ឈ្មោះនិងឧត្តមភាពក្នុងការបណ្តុះបណ្តាលនិងសិក្សាស្រាវជ្រាវ រយៈពេលជាង២ទសវត្សរ៍និងជាគ្រឹះស្ថានឧត្តមសិក្សាដ៏ធំជាងគេ**

- » *សាស្ត្រាចារ្យជាតិនិងអន្តរជាតិល្បីៗសរុបជាង៨០០នាក់*
- » *អតីតនិស្សិតនិងនិស្សិតសរុបជាង២ម៉ឺននាក់*
- » *រាជធានី-សាខាខេត្តសរុបចំនួន៩ស្ថិតក្នុង រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តតាកែវ ខេត្តបន្ទាយមានជ័យ ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ។*

✓ **ផ្តោតលើឧត្តមភាពនៃការស្រាវជ្រាវនិងបោះពុម្ពផ្សាយ**

- » *សាស្ត្រាចារ្យ និស្សិត និងអ្នកពាក់ព័ន្ធទាំងអស់ផ្តោតលើសកម្មភាពស្រាវជ្រាវនិងបោះពុម្ពផ្សាយ*
- » *មានទស្សនាវដ្តីស្រាវជ្រាវអន្តរជាតិ «International Journal of Business and Development Research» សម្រាប់សាស្ត្រាចារ្យ និស្សិតសិក្សាគ្រប់កម្រិត និងអ្នកស្រាវជ្រាវផ្សេងៗទៀត ដើម្បីបោះពុម្ពស្នាដៃ ស្រាវជ្រាវរបស់ពួកគេ*
- » *កំពុងសហប្រតិបត្តិការអនុវត្តន៍គម្រោងស្រាវជ្រាវ «៤ឆ្នាំ» អភិវឌ្ឍន៍កម្មវិធីសិក្សាកម្រិតតំបន់និងអន្តរជាតិរបស់សហគមន៍អ៊ឺរ៉ុប «Erasmus+Programme» ដែលមាន២២គ្រឹះស្ថានឧត្តមសិក្សាចូលរួមមាន៖ ប្រទេស Cyprus, ប្រទេស Portugal, ប្រទេស Greece, ប្រទេសកម្ពុជា, Malaysia, Philippines, Bangladesh, Bhutan និង Nepal ។*

✓ **មានធនធានរូបវន្តនិងធនធានសិក្សាគ្រប់គ្រាន់និងមានភាពទាន់សម័យ**

- » *មានបណ្ណាល័យ បន្ទប់សិក្សា និងបន្ទប់ពិសោធន៍គ្រប់គ្រាន់បំពាក់ដោយបច្ចេកវិទ្យាទាន់សម័យរួមទាំងបច្ចេកវិទ្យាឌីជីថលជួយឲ្យនិស្សិតទទួលបាននូវបទពិសោធន៍និងបង្កើតរបកគំហើញថ្មីតាមតម្រូវ ការសិក្សាស្រាវជ្រាវរបស់ពួកគេ។*
- » *មានធនធានបុគ្គលិកដែលមានបទពិសោធន៍និងវិជ្ជាជីវៈច្បាស់លាស់ព្រមទាំងធនធានសិក្សាគាំទ្រដល់ដំណើរការបណ្តុះបណ្តាល និងសិក្សាស្រាវជ្រាវរបស់និស្សិតគ្រប់កម្រិតនិងកម្មវិធីសិក្សា។*

✓ **មានបណ្តាញទំនាក់ទំនងសហប្រតិបត្តិការដ៏រឹងមាំជាមួយដៃគូរជាតិ អន្តរជាតិ និងអតីតនិស្សិត**

- » *ជាសមាជិកក្រុមប្រឹក្សាភិបាលនៃបណ្តាញសមាគមគ្រឹះស្ថានឧត្តមសិក្សាអន្តរជាតិ «ASAIHL» ដែលមានសមាជិក ២៦១ គ្រឹះស្ថាន មកពីប្រទេសចំនួន២៦ ក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ អាស៊ីនិងពិភពលោក*
- » *ជាសមាជិកក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា «CHEA» ដែលមានសមាជិកជាង១១៣គ្រឹះស្ថាន*
- » *ជាសមាជិកក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា នៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាដៃគូរកិច្ចព្រមព្រៀងសហប្រតិបត្តិការ ស្តីពីយន្តការតាក់តែងបង្កើតគោល នយោបាយ លិខិតបទដ្ឋានគតិយុត្តិ និងការដោះស្រាយវិវាទផ្សេងៗស្ថិតក្រោមសមត្ថកិច្ចក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់*
- » *កិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ស្តីពីការដាក់ឲ្យប្រើផ្ទាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh តាមប្រព័ន្ធ QR Codes គិតទាំងនៅលើសន្លឹកសញ្ញាបត្រសាកលវិទ្យាល័យបៀលប្រាយទាំងអស់ និងការរៀបចំប្រព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ*
- » *កិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយដៃគូរជាតិនិងអន្តរជាតិ ចំនួន ៣១ស្ថាប័ន ដែលកំពុងប្រតិបត្តិការក្នុងវិស័យជាច្រើនរួមមាន៖ បច្ចេកវិទ្យាព័ត៌មាន ធនាគារនិងហិរញ្ញវត្ថុ ធានារ៉ាប់រង ទេសចរណ៍ និងបដិសណ្ឋារកិច្ចវិស្វកម្មនិងស្ថាបត្យកម្ម ការអប់រំ សុខាភិបាល ការអភិវឌ្ឍន៍កសិកម្ម សហគ្រិនភាព និងអាជីវកម្មលក្ខណៈគ្រួសារ។ល។*

» អតីតនិស្សិតជាង ១០ ម៉ឺននាក់កំពុងបំពេញការងារនៅតាមស្ថាប័ននានា និងដឹកនាំអាជីវកម្មផ្ទាល់ខ្លួនលើវិស័យជាច្រើនដែលពួកគេបានសិក្សា ហើយបានបង្កើតអោយមានបណ្តាញទំនាក់ទំនងដ៏ធំជាមួយសាកលវិទ្យាល័យ និងនិស្សិតកំពុងសិក្សាជាង១ម៉ឺននាក់នៅតាមរាជធានី-សាខាខេត្តទាំង៩។

✓ **មានកម្មវិធីសិក្សាពហុជំនាញនិងឯកទេសជាច្រើនចាប់ពីកម្រិតបរិញ្ញាបត្ររងដល់កម្រិតបណ្ឌិតសរុបចំនួន ៥៩កម្មវិធីសិក្សា**

» កម្មវិធីកម្រិតបរិញ្ញាបត្ររង សរុបចំនួន ១៥ ជំនាញ/ឯកទេសសិក្សាក្នុងវិស័យ៖ គ្រប់គ្រងធុរកិច្ច នីតិសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ទេសចរណ៍និងបដិសណ្ឋារកិច្ច វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាព័ត៌មាន វិស្វកម្មនិងស្ថាបត្យកម្ម និង សិល្បៈមនុស្សសាស្ត្រនិងភាសា។ល។

» កម្មវិធីកម្រិតបរិញ្ញាបត្រ សរុបចំនួន ៣២ ជំនាញ/ឯកទេសសិក្សាក្នុងវិស័យ៖ គ្រប់គ្រងធុរកិច្ច នីតិសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ទេសចរណ៍និងបដិសណ្ឋារកិច្ច បច្ចេកវិទ្យាព័ត៌មាន សេដ្ឋកិច្ចនិងកសិកម្ម វិស្វកម្មនិងស្ថាបត្យកម្ម និង សិល្បៈមនុស្សសាស្ត្រនិងភាសា។ល។

» កម្មវិធីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ សរុបចំនួន ១០ ជំនាញសិក្សាក្នុងវិស័យ៖ គ្រប់គ្រងធុរកិច្ច នីតិសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បច្ចេកវិទ្យាព័ត៌មាន និង សិល្បៈ មនុស្សសាស្ត្រ និងភាសា។ ល។

» កម្មវិធីកម្រិតបណ្ឌិត សរុបចំនួន ២ ជំនាញសិក្សាក្នុងវិស័យ៖ គ្រប់គ្រងធុរកិច្ច និងសេដ្ឋកិច្ច។

✓ **ផ្តល់អាហារូបការណ៍និងសេវាគាំទ្រផ្នែកហិរញ្ញវត្ថុ**

» ផ្តល់អាហារូបករណ៍សិក្សា ១០០% ដល់សិស្សានុសិស្សដែលបានទទួលនិទ្ទេស A

» ផ្តល់អាហារូបករណ៍សិក្សាពី ១០% ទៅ ៣០% ដល់សិស្សានុសិស្សដែលមិនបានទទួលនិទ្ទេស A

» មានដៃគូសហប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនិងធនាគារចំនួន៣គ្រឹះស្ថានក្នុងការផ្តល់ សេវាឥណទានសិក្សា ១០០% លើថ្លៃសិក្សាដែលមានភាពងាយស្រួល និងតាមតម្រូវការរបស់សិស្សានុសិស្ស។

✓ **អនាគតអ្នកនឹងកាន់តែភ្លឺស្វាងជាមួយសាកលវិទ្យាល័យបៀលប្រាយ!**

» លទ្ធផលសិក្សាដ៏ជោគជ័យរបស់អ្នក នឹងផ្តល់ផលជះជាវិជ្ជមានដល់សង្គមក្នុងពេលអនាគត

» ការសិក្សាអប់រំដែលមានគុណភាពខ្ពស់ នវានុវត្តន៍ និងបរិយាបន្ន នឹងផ្តល់អំណាចដល់អ្នកសិក្សាពេញមួយជីវិតតាមរយៈកម្មវិធីសិក្សាប្រកបដោយបរិវត្តកម្ម បច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត «AI»៕








# កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ
## Associate and Bachelor's Degrees

| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
|---|---|
| **បរិញ្ញាបត្រសិល្បៈ «សិល្បៈសេរី ឬ វិទ្យាសាស្ត្រសង្គម»** | **Bachelor of Arts (B.A.) «Liberal Arts or Social Sciences»** |
| ✓ ជំនាញ **គ្រប់គ្រងទូទៅ** | ✓ in **General Management** |
| ✓ ជំនាញ **គណនេយ្យនិងហិរញ្ញវត្ថុ** | ✓ in **Accounting and Finance** |
| ✓ ជំនាញ **ធនាគារនិងហិរញ្ញវត្ថុ** | ✓ in **Finance and Banking** |
| ✓ ជំនាញ **ទីផ្សារ** | ✓ in **Marketing** |
| ✓ ជំនាញ **ធុរកិច្ចអន្តរជាតិ** | ✓ in **International Business** |





| កម្រិតបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ | Professional Degree |
|---|---|
| **បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច** | **Bachelor of Business Administration (B.B.A)** |
| ✓ ឯកទេស **គណនេយ្យ** | ✓ in **Accounting** |
| ✓ ឯកទេស **ហិរញ្ញវត្ថុ** | ✓ in **Finance** |
| ✓ ឯកទេស **ទីផ្សារ** | ✓ in **Marketing** |
| ✓ ឯកទេស **គ្រប់គ្រងធនធានមនុស្ស និងទំនាក់ទំនងវិជ្ជាជីវៈ** | ✓ in **Human Resource Management and Industrial Relations** |
| ✓ ឯកទេស **សហគ្រិនភាព និងការគ្រប់គ្រងសហគ្រាស** | ✓ in **Entrepreneurship and Enterprise Management** |

| បរិញ្ញាបត្ររងគ្រប់គ្រងធុរកិច្ច | Associate of Business Administration (A.B.A) |
|---|---|
| ✓ ឯកទេស **គណនេយ្យ** | ✓ in **Accounting** |
| ✓ ឯកទេស **ហិរញ្ញវត្ថុ** | ✓ in **Finance** |
| ✓ ឯកទេស **ទីផ្សារ** | ✓ in **Marketing** |
| ✓ ឯកទេស **គ្រប់គ្រងធនធានមនុស្ស និងទំនាក់ទំនងវិជ្ជាជីវៈ** | ✓ in **Human Resource Management and Industrial Relations** |
| ✓ ឯកទេស **សហគ្រិនភាព និងការគ្រប់គ្រងសហគ្រាស** | ✓ in **Entrepreneurship and Enterprise Management** |






## ឱកាសការងារ

- ✓ អ្នកគ្រប់គ្រងធនាគារ
- ✓ សហគ្រិនវ័យក្មេង
- ✓ អ្នកគ្រប់គ្រងរដ្ឋបាល និងគណនេយ្យ
- ✓ អ្នកគ្រប់គ្រងធនធានមនុស្ស
- ✓ អ្នកគ្រប់គ្រងហិរញ្ញវត្ថុ
- ✓ អ្នកគ្រប់គ្រងសវនកម្ម
- ✓ អ្នកគ្រប់គ្រងការនាំចេញនាំចូល
- ✓ អ្នកគ្រប់គ្រងធុរកិច្ចអន្តរជាតិ
- ✓ អ្នកគ្រប់គ្រងការដឹកជញ្ជូន
- ✓ អ្នកគ្រប់គ្រងស្តុក ឬ ឃ្លាំង
- ✓ គណនេយ្យករ និងសវនករ
- ✓ ធុរកិច្ចផ្ទាល់ខ្លួន និងបង្កើតការងារខ្លួនឯង
- ✓ អ្នកគ្រប់គ្រងអចលនទ្រព្យ
- ✓ អ្នកគ្រប់គ្រងផលិតកម្ម
- ✓ អ្នកគ្រប់គ្រងការលក់ និងទីផ្សារ
- ✓ អ្នកគ្រប់គ្រងភស្តុភារ
- ✓ អ្នកគ្រប់គ្រងកិច្ចសន្យា និងលទ្ធកម្ម
- ✓ អ្នកគ្រប់គ្រងផ្នែកបម្រើសេវាកម្មអតិថិជន
- ✓ សាស្ត្រាចារ្យ - គ្រូឧត្តមសិក្សា
- ✓ នៅតាមស្ថាប័នរដ្ឋ អង្គការ NGOs បណ្តាប្រទេសអាស៊ាន និងឱកាសការងារផ្សេងៗទៀត។





# កម្រិតបរិញ្ញាបត្រ
## Bachelor's Degree

| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
|---|---|
| បរិញ្ញាបត្រវិទ្យាសាស្ត្រ | Bachelor of Science (B.Sc.) |
| ✓ ជំនាញ **សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | ✓ in **Economics and Finance** |






| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
|---|---|
| បរិញ្ញាបត្រវិទ្យាសាស្ត្រ | Bachelor of Science (B.Sc.) |
| ✓ ជំនាញ **ផលិតកម្មកសិកម្មនិងទីផ្សារ** | ✓ in **Agricultural Production and Marketing** |





## ឱកាសការងារ ផ្នែកកសិកម្ម

- ✓ ជាមន្ត្រីនៅក្នុងរដ្ឋាភិបាល ក្រុមហ៊ុន អង្គការ និងផ្នែកឯកជន
- ✓ អ្នកឯកទេសផលិតកម្មដំណាំ
- ✓ អ្នកបង្កាត់ពូជរុក្ខជាតិ
- ✓ អ្នកស្រាវជ្រាវពូជដំណាំ
- ✓ អ្នកចែកចាយផលិតផល
- ✓ អ្នកបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ
- ✓ ជំនួយការស្រាវជ្រាវក្នុងបន្ទប់ពិសោធ
- ✓ មន្ត្រីភូតគាមអនាម័យ
- ✓ អ្នកឯកទេសសត្វ
- ✓ អ្នកផលិតចំណីសត្វ
- ✓ អ្នកពិនិត្យគុណភាពចំណីសត្វ
- ✓ អ្នកគ្រប់គ្រងសត្វ
- ✓ អ្នកបង្កាត់ពូជសត្វ
- ✓ អ្នកវិទ្យាសាស្ត្រកសិកម្ម
- ✓ អ្នកផ្តល់ព័ត៌មានទីផ្សារកសិផល
- ✓ អ្នកគ្រប់គ្រងទីផ្សារកសិកម្ម
- ✓ អ្នកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម
- ✓ អ្នកគ្រប់គ្រងឃ្លាំងស្តុកផលិតផល
- ✓ មន្ត្រីអធិការកិច្ច
- ✓ សាស្ត្រាចារ្យ - គ្រូឧត្តមសិក្សា
- ✓ បង្កើតកសិដ្ឋានផ្ទាល់ខ្លួន និងសហគ្រិនវ័យក្មេងក្នុងវិស័យកសិកម្ម និងឱកាសការងារផ្សេងៗទៀត

## ឱកាសការងារ ផ្នែកសេដ្ឋកិច្ច

- ✓ អ្នកស្រាវជ្រាវ វិភាគ ពិគ្រោះយោបល់ និងព្យាករណ៍ ផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ✓ អ្នកធ្វើផែនការ និងរៀបចំគោលនយោបាយ
- ✓ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ✓ ជាម្ចាស់ និងអ្នកគ្រប់គ្រងសហគ្រាស «ឧស្សាហកម្ម កសិកម្ម និងសេវាកម្ម»
- ✓ ភ្នាក់ងារជួញដូរមូលបត្រ
- ✓ ពាណិជ្ជករ
- ✓ មន្ត្រីពន្ធដារ និងស្ថាប័នគយ
- ✓ សាស្ត្រាចារ្យ
- ✓ មន្ត្រីនៅស្ថាប័នរដ្ឋ
- ✓ ធនាគារ និងអង្គការក្រៅរដ្ឋាភិបាល
- ✓ បុគ្គលិកក្រុមហ៊ុន ឯកជន និងអង្គការ NGOs និងឱកាសការងារផ្សេងៗទៀត





### លោក ឈឿង ឡុងឌី

បញ្ចប់កម្រិតបរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅឆ្នាំ២០១៦

បច្ចុប្បន្នជា ៖ អ្នកគ្រប់គ្រងក្រុមហ៊ុន ZTO Express Cambodia សាខាខេត្តកំពង់ចាម។ «ការសិក្សាជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅសាកលវិទ្យាល័យបៀលប្រាយបានធ្វើឲ្យខ្ញុំអាចពង្រឹងសមត្ថភាពលើចំណេះដឹងនិងចំណេះធ្វើពិតប្រាកដដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដែលមានការប្រកួតប្រជែងខ្លាំង។»



### លោក ធី ផានិត

បញ្ចប់កម្រិតបរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញ ផលិតកម្មកសិកម្មនិងទីផ្សារ នៅឆ្នាំ២០២៤

បច្ចុប្បន្នជា ៖ មន្ត្រីជំនួយការក្នុងមន្ទីរពិសោធន៍ ទាក់ទងនឹងទឹក ចំណីអាហារ និងសារធាតុគីមីនៅអង្គការទឹកដើម្បីកម្ពុជា «Water for Cambodia»

«ការសិក្សាជំនាញផលិតកម្មកសិកម្មនិងទីផ្សារនៅសាកលវិទ្យាល័យបៀលប្រាយ យើងសិក្សាទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅក្នុងសួនកសិកម្ម និងការចុះអនុវត្តតាមបណ្តាកសិដ្ឋាននានា ហើយមិនតែប៉ុណ្ណោះ សាស្ត្រាចារ្យបង្រៀនក្នុងមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្មពោរពេញដោយសមត្ថភាព និងបទពិសោធន៍ការងារនៅក្នុងវិស័យកសិកម្ម។»

# កន្លែងពិសោធន៍និងចុះកម្មសិក្សាកសិកម្ម
# Agriculture & Internship Laboratory
















# កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ
## Associate and Bachelor's Degrees

| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
|---|---|
| បរិញ្ញាបត្រសិល្បៈ «សិល្បៈសេរី ឬ វិទ្យាសាស្ត្រសង្គម» | Bachelor of Arts (B.A.) «Liberal Arts or Social Sciences» |
| ✓ ជំនាញ **នីតិសាស្ត្រ** | ✓ in **Law** |





| កម្រិតបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ | Professional Degree |
|---|---|
| បរិញ្ញាបត្រឯកទេសនីតិសាស្ត្រ | Bachelor of Laws (LL.B.) |
| បរិញ្ញាបត្ររងឯកទេសនីតិសាស្ត្រ | Associate of Laws (LL.A.) |






| បរិញ្ញាបត្ររដ្ឋបាលសាធារណៈ | Bachelor of Public Administration (B.P.A) |
|---|---|
| ✓ ឯកទេស **គ្រប់គ្រងសាធារណៈនិងអភិបាលកិច្ច** | ✓ in **Public Management and Governance** |





| បរិញ្ញាបត្ររងរដ្ឋបាលសាធារណៈ | Associate of Public Administration (A.P.A) |
|---|---|
| ✓ ឯកទេស **គ្រប់គ្រងសាធារណៈនិងអភិបាលកិច្ច** | ✓ in **Public Management and Governance** |





## ឱកាសការងារ

- ✓ ចៅក្រម
- ✓ ព្រះរាជអាជ្ញា
- ✓ មេធាវី
- ✓ ក្រឡាបញ្ជី
- ✓ សារការី
- ✓ អាជ្ញាសាលា
- ✓ មន្ត្រីច្បាប់
- ✓ ទីប្រឹក្សាច្បាប់
- ✓ ជំនួយការផ្នែកច្បាប់
- ✓ មជ្ឈត្តករ
- ✓ ឧត្តមមន្ត្រី
- ✓ សាស្ត្រាចារ្យ - គ្រូឧត្តមសិក្សា
- ✓ នៅតាមស្ថាប័នរដ្ឋ អង្គការ NGOs បណ្តាប្រទេសអាស៊ាន និង ឱកាសការងារផ្សេងៗទៀត។

## បន្ទប់តុលាការប្រតិដ្ឋ | Mock Courtroom


















# កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ
## Associate and Bachelor's Degrees

| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
|---|---|
| បរិញ្ញាបត្រសិល្បៈ «សិល្បៈសេរី ឬ វិទ្យាសាស្ត្រសង្គម» | Bachelor of Arts (B.A.) «Liberal Arts or Social Sciences» |
| ✓ ជំនាញ គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច | ✓ in Tourism and Hospitality Management |



| កម្រិតបណ្ឌុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ | Professional Degree |
|---|---|
| បរិញ្ញាបត្រឯកទេសគ្រប់គ្រងទេសចរណ៍ | Bachelor of Tourism Management (B.T.M) |
| បរិញ្ញាបត្ររងឯកទេសគ្រប់គ្រងទេសចរណ៍ | Associate of Tourism Management (A.T.M) |










## ឱកាសការងារ

- ✓ អ្នកគ្រប់គ្រងទូទៅក្នុងសណ្ឋាគារ ភោជនីយដ្ឋាន
- ✓ អ្នកគ្រប់គ្រងក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍
- ✓ អ្នករៀបចំកម្មវិធីកម្រិតជាតិនិងអន្តរជាតិ
- ✓ អ្នកគ្រប់គ្រងបដិសណ្ឋារកិច្ច
- ✓ អ្នកពិគ្រោះយោបល់ក្នុងវិស័យទេសចរណ៍
- ✓ មន្ត្រីរដ្ឋាភិបាលនៅតាមក្រសួង - ស្ថាប័ននានា
- ✓ មន្ទីរទេសចរណ៍ - អាជ្ញាធរអប្សរា
- ✓ មន្ត្រីអង្គការមិនមែនរដ្ឋាភិបាល
- ✓ មគ្គុទេសក៍ទេសចរណ៍
- ✓ អ្នកគ្រប់គ្រងក្រុមហ៊ុនដឹកជញ្ជូន
- ✓ អ្នកគ្រប់គ្រងការីទេសចរណ៍
- ✓ អ្នកគ្រប់គ្រងការិយាល័យជួរមុខ
- ✓ អ្នកគ្រប់គ្រងបានីយដ្ឋាន
- ✓ អ្នកគ្រប់គ្រងកាស៊ីណូ
- ✓ អ្នកគ្រប់គ្រងរមណីយដ្ឋាន
- ✓ អ្នកគ្រប់គ្រងគេហកិច្ច
- ✓ សាស្ត្រាចារ្យ - គ្រូឧត្តមសិក្សា
- ✓ ម្ចាស់អាជីវកម្មផ្ទាល់ខ្លួន និងសហគ្រិនវ័យក្មេង
- ✓ នៅតាមស្ថាប័នរដ្ឋ អង្គការ NGOs បណ្តាប្រទេសអាស៊ាន និងឱកាសការងារផ្សេងៗទៀត។



### កញ្ញា រឿន ចាន់មករា

បញ្ចប់កម្រិតបរិញ្ញាបត្រសិល្បៈ ជំនាញ គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច នៅឆ្នាំ២០២៣
បច្ចុប្បន្នជា៖ Secretary នៅក្រុមហ៊ុន Mengly J.Quach Education
«ការសិក្សាគ្រប់មុខវិជ្ជានៅក្នុងមហាវិទ្យាល័យរបស់ខ្ញុំ គឺទទួលបានការបង្រៀនយ៉ាងយកចិត្តទុកដាក់ស៊ីជម្រៅពីសំណាក់សាស្ត្រាចារ្យដែលមានជំនាញពាក់ព័ន្ធនឹង បដិសណ្ឋារកិច្ចយ៉ាងច្បាស់ដែលធ្វើឲ្យខ្ញុំអាចយកមកអនុវត្តក្នុងការងារបានរីកចម្រើនបានលឿនបំផុត»



### លោក សៀន បណ្ឌិត

បញ្ចប់កម្រិតបរិញ្ញាបត្រសិល្បៈ ជំនាញ គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច នៅឆ្នាំ២០២៣
បច្ចុប្បន្នជា៖ ប្រធានគ្រប់គ្រងភ្នាក់ងារទេសចរណ៍ នៅប្រាសាទបន្ទាយសំរ៉ែ និងភ្នំបូក នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា «បន្ទាប់ពីបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យបៀលប្រាយ ធ្វើឲ្យខ្ញុំមានសមត្ថភាពពេញលេញ ក្នុងការបំពេញការងារ»

# កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ
# Associate and Bachelor's Degrees

| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
| --- | --- |
| បរិញ្ញាបត្រវិទ្យាសាស្ត្រ | Bachelor of Science (B.Sc.) |
| ✓ ជំនាញ **បច្ចេកវិទ្យាព័ត៌មាន** | ✓ in **Information Technology** |
| ✓ ជំនាញ **រចនាប្រព័ន្ធផ្សព្វផ្សាយឌីជីថល** | ✓ in **Digital Media Design** |





| កម្រិតបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ | Professional Degree |
| --- | --- |
| បរិញ្ញាបត្របច្ចេកវិទ្យាព័ត៌មាន | Bachelor of Information Technology (B.I.T) |
| បរិញ្ញាបត្ររងបច្ចេកវិទ្យាព័ត៌មាន | Associate of Information Technology (A.I.T) |





| | |
|---|---|
| **បរិញ្ញាបត្ររចនាប្រព័ន្ធផ្សព្វផ្សាយឌីជីថល** | **Bachelor of Digital Media Design (B.D.M)** |
| **បរិញ្ញាបត្ររងរចនាប្រព័ន្ធផ្សព្វផ្សាយឌីជីថល** | **Associate of Digital Media Design (A.D.M)** |

## ហេតុអ្វីបានត្រូវសិក្សាជំនាញ រចនាប្រព័ន្ធផ្សព្វផ្សាយឌីជីថល នៅបៀលប្រាយ?

សាកលវិទ្យាល័យបៀលប្រាយ បានបង្កើតមុខជំនាញថ្មីគឺ **រចនាប្រព័ន្ធផ្សព្វផ្សាយឌីជីថល «Digital Media Design»** ក្នុងដេប៉ាដឺម៉ង់បច្ចេកវិទ្យាព័ត៌មាននៃមហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលមានគោលបំណងផ្តល់និស្សិតនូវជំនាញទាន់សម័យក្នុងរចនាមាតិកាឌីជីថល ដូចជា៖

» ការប្រើប្រាស់ម៉ាស៊ីនថត ការចាប់ប្លង់ ការគ្រប់គ្រងពន្លឺធម្មជាតិ និងពន្លឺសិប្បនិម្មិត (ឧបករណ៍ពន្លឺ)
» ការរចនាក្រាហ្វិក កាត់តវីដេអូ ការផលិតវីដេអូ ក្រាហ្វិកចលនា និងគំរូ 2D/3D ម៉ូដែល
» បង្កើតមាតិកាឌីជីថល ឬផលិតវីដេអូដែលមានភាពទាក់ទាញ និងមានគុណភាពខ្ពស់ក្នុងសម័យឌីជីថល
» ការសិក្សាអំពីទីផ្សារឌីជីថលដែលជាគន្លឹះសម្រាប់ការផ្សព្វផ្សាយអាជីវកម្មក្នុងសម័យបច្ចេកវិទ្យាបច្ចុប្បន្ន
» ដើម្បីបំពេញតម្រូវការទីផ្សារការងារដែលកំពុងតែស្វែងរកជំនាញនេះនិងមាតិកាឌីជីថលកំពុងមានតម្រូវការខ្លាំង
» ផ្តល់ឱកាសឲ្យនិស្សិតទទួលបានបទពិសោធន៍ជាក់ស្តែងក្នុងការរចនា និងវេទិកាឌីជីថលផ្សេងៗ
» ជាជម្រើសដ៏ល្អសម្រាប់អ្នកដែលចូលចិត្តទៅក្នុងវិស័យឌីជីថល ដែលកំពុងត្រូវការខ្លាំងនៅលើទីផ្សារការងារ។



# ↘ បន្ទប់ពិសោធន៍កុំព្យូទ័រ | Computer Laboratory





















# កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ
## Associate and Bachelor's Degrees

| កម្រិតអប់រំឧត្តមសិក្សា | Academic Degree |
|---|---|
| **បរិញ្ញាបត្រវិទ្យាសាស្ត្រ** | **Bachelor of Science (B.Sc.)** |
| ✓ ជំនាញ **វិស្វកម្មសំណង់ស៊ីវិលអគារ** | ✓ in **Building Civil Engineering** |
| ✓ ជំនាញ **វិស្វកម្មសំណង់ស៊ីវិលស្ពានថ្នល់** | ✓ in **Bridge and Highway Civil Engineering** |






| | |
|---|---|
